NSW GOVERNMENT | Environment, Climate Change & Water

Khmer

# ការថែរក្សាកំណត់ត្រានៃថ្នាំសម្លាប់សត្វចង្រៃដែលអ្នកប្រើប្រាស់

## តើច្បាប់ថ្មីនេះចែងដូចម្តេចខ្លះ?

ច្បាប់ថ្នាំសម្លាប់សត្វចង្រៃ ឆ្នាំ២០០៩ (Pesticides Regulation 2009) ចែងថា:

ប្រសិនបើអ្នកប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ ទៅលើផលកសិដ្ឋាន ឬទៅលើកសិដ្ឋាន ឬនៅក្នុងរបរជំនួញ ឬនៅក្នុងការងាររបស់អ្នក អ្នកត្រូវធ្វើកំណត់ត្រាអំពីថ្នាំសម្លាប់សត្វចង្រៃដែលអ្នកប្រើប្រាស់។

- កំណត់ត្រាដែលអ្នកបានធ្វើ ត្រូវរួមបញ្ចូលនូវពត៌មានដូចតទៅ: អ្នកណាជាអ្នកប្រើ ប្រភេទថ្នាំ ពេលវេលា វិធីសាស្ត្រប្រើ ទីកន្លែង វត្ថុដែលជាកម្មវត្ថុនៃការប្រើប្រាស់ថ្នាំ និងបរិមាណថ្នាំដែលបានប្រើប្រាស់។ ប្រសិនបើថ្នាំសម្លាប់សត្វចង្រៃត្រូវបានប្រើនៅលើទីវាលដោយឧបករណ៍បាញ់ អ្នកត្រូវធ្វើការប៉ាន់ស្មានអំពីល្បឿនខ្យល់ និងទិសដៅរបស់វា។
- កំណត់ត្រាត្រូវតម្រូវឲ្យធ្វើនៅក្នុងកំឡុងពេល២៤ម៉ោងនៃការប្រើប្រាស់ថ្នាំ ហើយត្រូវរក្សាទុករយៈពេល៣ឆ្នាំ។
- អាជ្ញាធរដែលមានការអនុញ្ញាតមកពីក្រសួងថែរក្សាបរិដ្ឋាន ការផ្លាស់ប្តូរអាកាសធាតុ និងទឹករដ្ឋញូវសៅវែល (Department of Environment, Climate Change and Water (DECCW)) អាចធ្វើការត្រួតពិនិត្យកំណត់ត្រាទាំងនោះ នៅគ្រប់ពេលវេលាដែលសមស្រប និងអាចធ្វើការផាកពិន័យ ក្នុងករណីកំណត់ត្រាទាំងនោះពុំត្រូវបានថែរក្សាឲ្យបានត្រឹមត្រូវតាមការកំណត់។

## តើថ្នាំសម្លាប់សត្វចង្រៃណាខ្លះត្រូវបានដាក់បញ្ចូល?

ថ្នាំសម្លាប់សត្វចង្រៃមានរួមទាំងថ្នាំសម្លាប់រុក្ខជាតិចង្រៃ ថ្នាំសម្លាប់រុក្ខជាតិពពួកផ្សិត សម្លាប់សត្វល្អិត ថ្នាំបាញ់សំរាប់សម្លាប់សត្វល្អិតសម្លាប់បាក់តេរី ថ្នាំសម្លាប់ពពួកសត្វកកេរ នុយសម្រាប់ចាប់សត្វ នុយបំពុលសត្វ ថ្នាំបណ្តេញសត្វ និងប្រភេទថ្នាំដែលប្រើដើម្បីការពារប៉ារ៉ាស៊ីតសំរាប់សត្វ។

## តើច្បាប់នេះមានសុពលភាពទៅលើអ្នកណាខ្លះ?

កំណត់ត្រាត្រូវតម្រូវឲ្យរក្សាទុក ចំពោះអ្នកទាំងឡាយណាដែលប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃនៅក្នុងរបរអាជីវកម្ម ឬនៅក្នុងតួនាទីរបស់ខ្លួនដូចជាទៅលើកសិដ្ឋាន ឬផលិតផលកសិដ្ឋាន ឬជាផ្នែកណាមួយនៃអាជីវកម្ម ឬតួនាទីរបស់ខ្លួន។

ជាឧទាហរណ៍ ច្បាប់នេះសំដៅទៅលើកសិករ (farmers), អ្នកដាំបន្លែ (market gardeners), អ្នកថែរក្សាវាលលេងហ្គោល (green keepers), អ្នកថែច្បារ (nursery operators), អ្នកត្រួតពិនិត្យលើពពួកសត្វចង្រៃ (pest control operators), អ្នកត្រួតពិនិត្យដី (ground-rig operators), ម្ចាស់ដី (landlords), អ្នករចនាសួនច្បារ (landscape gardeners), ភ្នាក់ងារសាលាក្រុង និងរដ្ឋាភិបាលដែលបានប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ។

អ្នកបាញ់ថ្នាំពីលើអាកាស ត្រូវបានតម្រូវរួចហើយឲ្យរក្សាទុកកំណត់ត្រារបស់គេ នេះគឺជាផ្នែកមួយនៃលិខិតអនុញ្ញាតនៅក្រោមច្បាប់បញ្ញត្តិ *ថ្នាំសម្លាប់សត្វចង្រៃ ឆ្នាំ១៩៩៩*។ ច្បាប់ស្តីពីថ្នាំសម្លាប់សត្វចង្រៃនេះក៏បានតម្រូវផងដែរឲ្យធ្វើកំណត់ត្រាអំពីពត៌មានផ្សេងបន្ថែមទៀត។

កំណត់ចំណាំសំខាន់: ជនគ្រប់រូបដែលប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃគ្រប់ប្រភេទ ត្រូវគោរពតាមសេចក្តីណែនាំដែលបិទជាប់មកជាមួយផលិតផល ដូចមានចែងរួចមកហើយនៅក្នុងច្បាប់ស្តីពី *ថ្នាំសម្លាប់សត្វចង្រៃ ឆ្នាំ១៩៩៩* (Pesticides Act 1999)។ ដូច្នេះប្រសិនបើសេចក្តីណែនាំនោះ ឬលិខិតអនុញ្ញាតរបស់អាជ្ញាធរអូស្ត្រាលីទទួលបន្ទុកការចុះបញ្ជីថ្នាំសម្លាប់សត្វចង្រៃ ការព្យាបាលសត្វ និងថ្នាំពេទ្យ (APVMA) តម្រូវឲ្យអ្នកធ្វើកំណត់ត្រានោះ អ្នកដាច់ខាតត្រូវតែគោរពតាម ដោយមិនគិតពីផលប៉ះពាល់ដែលអាចកើតមានឡើងពីបទបញ្ញត្តិនេះមកលើរូបអ្នកឡើយ។

## តើខ្ញុំត្រូវតម្រូវឲ្យធ្វើកំណត់ត្រាស្តីអំពីការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃនៅក្នុងផ្ទះដែរឬទេ?

អ្នកមិនតម្រូវឲ្យធ្វើកំណត់ត្រាទេ នៅពេលដែលអ្នកប្រើប្រាស់ថ្នាំទាំងនោះនៅជុំវិញផ្ទះ សួនច្បាររបស់អ្នក ឬនៅពេលដែលអ្នកប្រើប្រាស់ថ្នាំប្រភេទសំរាប់បណ្តេញសត្វល្អិត។ ឧទាហរណ៍ អ្នកមិនបានតម្រូវឲ្យធ្វើកំណត់ត្រាស្តីអំពីការប្រើប្រាស់ថ្នាំកន្ទាត ថ្នាំសម្លាប់ចៃលើសត្វចិញ្ចឹម ឬថ្នាំសម្លាប់សត្វចង្រៃដែលប្រើលើថ្នាលបន្លែក្នុងបរិវេណផ្ទះ ឬសំរាប់ប្រើលើដើមឈើហូបផ្លែទេ។

## តើការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃប្រភេទណាខ្លះដែលតម្រូវឲ្យមានការធ្វើកំណត់ត្រា?

ស្ថានភាពដែលតម្រូវឲ្យអ្នកធ្វើកំណត់ត្រាស្តីអំពីការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃនោះរួមមាន:

- បាញ់ថ្នាំលើដំណាំ ឬផលិតផលកសិដ្ឋានផ្សេងៗទៀត
- បាញ់ថ្នាំទៅលើដីទំនេរដែលគ្មានដំណាំ (ឧទាហរណ៍ បាញ់ថ្នាំមុនពេលដាំដំណាំ ឬក្រោយពេលប្រមូលផល)
- ត្រាំផ្លែឈើ ឬបន្លែ
- ដាក់នុយសត្វផ្សេងៗដូចជាទន្សាយ កញ្ជ្រោង ឆ្កែព្រៃ ជ្រូកព្រៃ។ល។
- បង្ក្រាបសត្វចង្រៃនៅក្នុង ឬជុំវិញលំនៅដ្ឋាន (ពុំសំដៅទៅលើការប្រើប្រាស់ក្នុងកសិដ្ឋាន ឬក្នុងវិស័យរុក្ខាប្រមាញ់ទេ)
- បាញ់ទៅលើកន្លែងផ្សេងៗ ដូចជាទីធ្លាសំរាប់លេងហ្គោល ឬលេងប៊ូល (bowling greens) ទីធ្លាសំរាប់លេងកំសាន្ត ឬទីធ្លាតាមចិញ្ចើមថ្នល់ សួនឈើ និងសួនច្បារ។
- សំរាប់ការពារបសុសត្វពីពពួកប៉ារ៉ាស៊ីតពីខាងក្រៅ (លើកលែងតែក្នុងករណីប្រើប្រាស់ឧបករណ៍ដែលប្រើដោយដៃ)។

Pesticides

អ្នកដាំបន្លែ និងផ្លែឈើគ្រប់ប្រភេទ និងសាកវប្បករទាំងឡាយត្រូវតែរក្សាកំណត់ត្រាអំពីការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃទាំងអស់ លើកលែងតែក្នុងករណីដែលប្រើថ្នាំទាំងនោះ សំរាប់បាញ់ទៅលើដើមរុក្ខជាតិ ដែលនៅចម្ងាយយ៉ាងហោចណាស់២០ម៉ែត្រពីព្រំប្រទល់ដីដែលនៅជិតបំផុត ហើយការបាញ់នោះត្រូវធ្វើឡើងដោយប្រើឧបករណ៍ដែលប្រើដៃ និងដើរដោយដៃផង។

## *តើខ្ញុំត្រូវតម្រូវឲ្យធ្វើកំណត់ត្រាអំពីអ្វីខ្លះ?*

អ្នកត្រូវសរសេរចុះពត៌មានអំពី:



### តើអ្នកណាជាអ្នកប្រើប្រាស់ថ្នាំនោះ?

កត់ឈ្មោះ អាស័យដ្ឋាន លេខទូរស័ព្ទសំរាប់ទំនាក់ទំនងរបស់អ្នកប្រើប្រាស់ថ្នាំនោះ។ ប្រសិនបើអ្នកម៉ៅការ ឬបុគ្គលិកជាអ្នកប្រើប្រាស់ថ្នាំនោះ ជននោះត្រូវធ្វើការកត់ត្រាឈ្មោះរបស់ពួកគេ ព្រមទាំងឈ្មោះ អាស័យដ្ឋាន និងពត៌មានលំអិតរបស់និយោជកពួកគេ។

ឈ្មោះ អាស័យដ្ឋាន និងពត៌មានសំរាប់ទាក់ទងលំអិតត្រូវឲ្យមានលក្ខណៈគ្រប់គ្រាន់។ ឧទាហរណ៍ ត្រូវធ្វើការកត់ត្រានូវនាម និងគោត្តនាម (មិនមែនឈ្មោះហៅក្រៅ) អាស័យដ្ឋានពេញលេញរបស់ដី និងលេខទូរស័ព្ទ និងអាស័យដ្ឋាន អ៊ីម៉េល លេខទូរសារ និងទូរស័ព្ទចល័ត ប្រសិនបើមាន។

ប្រសិនបើអ្នក ជាអ្នកមើលការខុសត្រូវនៅលើការដ្ឋានដោយផ្ទាល់ សំរាប់អាជ្ញាធរសាធារណៈ អ្នកត្រូវធ្វើការកត់ត្រាឈ្មោះរបស់បុគ្គលិកស្ម័គ្រចិត្ត ឬបុគ្គលិកដែលទទួលប្រាក់កំរៃទាំងអស់ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អ្នក ក្នុងការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃនោះ។

### តើអ្នកណាដែលជាម្ចាស់ ឬអ្នកគ្រប់គ្រងដីដែលថ្នាំនោះកំពុងប្រើប្រាស់?

កត់ឈ្មោះ អាស័យដ្ឋាន និងពត៌មានលំអិតសំរាប់ទាក់ទងរបស់អ្នកដែលគ្រប់គ្រងទីកន្លែងដែលថ្នាំនោះកំពុងប្រើប្រាស់។ អ្នកទាំងនោះអាចជាម្ចាស់ដី អ្នកគ្រប់គ្រងដី ឬអ្នកជួល។

ដូចដែលបានបញ្ជាក់ពីខាងលើ ឈ្មោះ និងពត៌មានលំអិតសំរាប់ទំនាក់ទំនងត្រូវមានលក្ខណៈគ្រប់គ្រាន់។




### តើអ្នកបានប្រើប្រាស់ថ្នាំនោះនៅពេលណា?

អ្នកត្រូវធ្វើការកត់ត្រានៅថ្ងៃខែឆ្នាំ និងពេលវេលាដែលអ្នកចាប់ផ្តើម និងបញ្ចប់ការប្រើប្រាស់ថ្នាំនោះ។



### តើថ្នាំអ្វីដែលអ្នកបានប្រើប្រាស់?

អ្នកត្រូវធ្វើការកត់ត្រាឈ្មោះពេញរបស់ថ្នាំដែលអ្នកបានប្រើ។ ឈ្មោះនោះជាទូទៅអ្នកអាចរកឃើញនៅក្រោមផ្លាកសញ្ញាព្រមានដែលមានបិទភ្ជាប់មកជាមួយនឹងផលិតផល និងនៅពីលើពត៌មានដែលប្រាប់អំពីធាតុផ្សំ។ ឈ្មោះផលិតផលទាំងនោះអាចរួមបញ្ចូលនូវអក្សរ លេខដែលជាផ្នែកមួយរបស់ឈ្មោះដែរ ដូច្នេះហើយអ្នកក៏តម្រូវឲ្យកត់ត្រានូវអក្សរ និងលេខទាំងនោះផងដែរ។ ឧទាហរណ៍ ‘glyphosate’ មានលក្ខណៈពុំគ្រប់គ្រាន់ទេលុះត្រាតែបន្ថែមនូវ ‘Bloggs Glyphosate 360 Herbicide’ ទើបអាចយកជាការបាន។

ប្រសិនបើអ្នកប្រើប្រាស់ថ្នាំទាំងនោះដោយវិធីណាមួយផ្សេងពីសេចក្តីណែនាំដែលមានភ្ជាប់មកជាមួយផលិតផល ហើយវិធីដែលអ្នកប្រើនោះទទួលបានការអនុញ្ញាតពីអាជ្ញាធរជាតិទទួលបន្ទុកការចុះបញ្ជី APVMA ក៏ដោយ ក៏អ្នកនៅតែតម្រូវឲ្យធ្វើការកត់ត្រានូវឈ្មោះពេញរបស់ផលិតផលដែលអ្នកបានប្រើប្រាស់ដែរ។ អ្នកក៏ត្រូវឲ្យប្រាកដផងដែរថាអ្នកបានអាននូវលិខិតអនុញ្ញាតនោះ (ឬឲ្យអ្នកផ្សេងអានឲ្យអ្នកស្តាប់) ដើម្បីឲ្យប្រាកដថាអ្នកមានការយល់ដឹងអំពីវិធីនៃការប្រើប្រាស់ថ្នាំនោះ។ អ្នកពុំតម្រូវឲ្យកត់ត្រានូវលេខលិខិតអនុញ្ញាតទេ ប៉ុន្តែអាជ្ញាធរការពារបរិស្ថាន DECCW យល់ថាអ្នកគួរតែធ្វើការកត់ត្រាលេខទាំងនោះផងដែរ។



### តើអ្នកប្រើប្រាស់ថ្នាំនោះសំរាប់រុក្ខជាតិ ឬស្ថានភាពបែបណាដែរ?

បញ្ជាក់ឈ្មោះដំណាំ ឬស្ថានភាពដែលអ្នកបានប្រើប្រាស់ថ្នាំនោះ។ ឧទាហរណ៍ ស្រូវសាលី វ៉ាន់ស៊ុយ (coriander), ឬ (macadamia), ឬផ្កា (chrysanthemums), ឬសំរាប់ស្ថានភាពដូចជាដីទំនេរ ឬប្រើប្រាស់ថ្នាំទាំងនោះនៅក្នុងផ្ទះ។ ប្រសិនបើផ្លាកសញ្ញាដែលមានបិទភ្ជាប់ជាមួយផលិតផលបញ្ជាក់ថាសំរាប់ប្រើជាមួយបន្លែ អ្នកក៏នៅតែតម្រូវឲ្យកត់ឈ្មោះបន្លែដែលអ្នកបានប្រើថ្នាំនោះបាញ់ទៅលើ។ ឧទាហរណ៍ អ្នកត្រូវកត់ថា ស្ពៃណាច (spinach) និងខ្ទឹមបារាំង (onions) ពុំមែនគ្រាន់តែពាក្យថា ’បន្លែ’ នោះគ្រប់គ្រាន់ទេ។ DECCW យល់ឃើញថាវាជាការមួយដ៏ប្រសើរផងដែរ ដែលអ្នកត្រូវធ្វើការកត់ត្រាអំពីប្រភេទជម្ងឺ ឬសត្វល្អិតដែលអ្នកកំពុងកំចាត់។



### តើអ្នកប្រើប្រាស់ថ្នាំទាំងនោះដោយវិធីណា?

បញ្ជាក់ឈ្មោះឧបករណ៍ដែលអ្នកបានប្រើ ដូចជាម៉ាស៊ីនបាញ់អ័ព្ទតិច (mister), ម៉ាស៊ីនបាញ់អ័ព្ទច្រើន(fogger), ប្រដាប់ស្ពាយ(backpack), ប្រដាប់ជូត (wiper), ប្រដាប់ខ្វងពិនិត្យដី(ground-rig), ម៉ាស៊ីនបាញ់ពីរថយន្ត (truck-mounted boom), ម៉ាស៊ីនបាញ់ពីត្រាក់ទ័រ (tractor-mounted boomsprayer) ជាដើម

DECCW ស្នើថាអ្នកគួរតែធ្វើការកត់ត្រាផងដែរនូវទំហំក្បាលទុយយោ និងរង្វាស់ខ្នាតផ្សេងៗទៀត ដែលទាំងអស់នេះនឹងបញ្ជាក់នូវការយកចិត្តទុកដាក់របស់អ្នក ក្នុងការការពារអំពីផលប៉ះពាល់ដែលអាចកើតមានឡើងដោយការសាយភាយរបស់ថ្នាំ។







## តើអ្នកបានប្រើថ្នាំនោះអស់បរិមាណប៉ុណ្ណា?

ធ្វើការកត់ត្រានូវបរិមាណទាំងអស់នៃថ្នាំដែលអ្នកបានលាយបញ្ចូលគ្នា និងបានប្រើប្រាស់ព្រមជាមួយនឹងអត្រាដែលអ្នកបានប្រើ។ អ្នកអាចធ្វើការកត់ត្រាអំពីអត្រានៃការប្រើប្រាស់ថ្នាំតាមវិធីណាមួយដែលអ្នកពេញចិត្ត គឺឲ្យតែអ្នកបញ្ជាក់បានច្បាស់អំពីបរិមាណថ្នាំដែលបានប្រើ (ទោះថារូបមន្តនៃការលាយថ្នាំ ឬថ្នាំដែលបានលាយរួចជាស្រេច) និងទំហំដីដែលអ្នកប្រើប្រាស់ថ្នាំនោះ (ឧទាហរណ៍ ទំហំជាម៉ែត្រការ៉េ ឬហិកតា)។




## តើទីកន្លែងណាដែលអ្នកប្រើថ្នាំទាំងនោះ?

ធ្វើការកត់ត្រានូវអាស័យដ្ឋានរបស់ដី និងរៀបរាប់អំពីតំបន់ដែលថ្នាំនោះបានប្រើ។ អ្នកអាចប្រើគំនូសពង្រាង ឬផែនទីដែលមានសញ្ញាសំគាល់អំពីលំនៅដ្ឋាន និងវាលស្រែ ឬចំការ ដើម្បីបង្ហាញអំពីទីតាំងពិតប្រាកដរបស់ដី ដែលអ្នកបានប្រើប្រាស់ថ្នាំនោះ។

ម្យ៉ាងវិញទៀត ការកត់ត្រារបស់អ្នកអាចផ្អែកទៅលើតំបន់ដែលមាននៅក្នុងផែនទីទីតាំងដីរបស់អ្នក ដែលបង្ហាញនូវផ្លូវព័ទ្ធជុំវិញ របងផ្លូវទឹក និងសញ្ញាសំគាល់ទីតាំង ដែលបញ្ជាក់នូវព្រំប្រទល់របស់ដីនោះ។ ការកត់ត្រានោះក៏តម្រូវឲ្យមានផងដែរនូវទីតាំង ឬផ្នែកណាមួយនៃដីដែលអ្នកបានប្រើប្រាស់ថ្នាំ។

សំរាប់ការប្រើប្រាស់ក្នុងវិស័យកសិកម្ម ឬរុក្ខាប្រមាញ់ អ្នកក៏តម្រូវឲ្យធ្វើការកត់ត្រានូវលំដាប់លំដោយ នៃការប្រើប្រាស់ថ្នាំនោះទៅលើផ្នែកណាមួយនៃដី ប្រសិនបើអ្នកត្រូវបាញ់ថ្នាំច្រើនផ្នែកក្នុងមុខការជាមួយគ្នា។ ឧទាហរណ៍ អ្នកត្រូវកត់ថាបាន ʹបាញ់ថ្នាំតាមលំដាប់លំដោយទៅលើដីផ្នែកទី១ ទី៥ ទី២ និងទី៣ʹ។






## អំពីធាតុអាកាស - ល្បឿនខ្យល់ និងទិសដៅខ្យល់?

ប្រសិនបើអ្នកប្រើប្រាស់ថ្នាំទាំងនោះ**បាញ់ទៅក្នុងខ្យល់នៅលើទីវាល** អ្នកតម្រូវឲ្យធ្វើការកត់ត្រាដោយប៉ាន់ស្មាននូវកម្លាំងខ្យល់ និងទិសដៅរបស់វា។ ឧទាហរណ៍ ខ្យល់ជំនោរបក់ស្រាលៗពីទិសខាងជើងឈៀងខាងកើត។ អ្នកពុំចាំបាច់មានឧបករណ៍ពិសេស សំរាប់ធ្វើការវាស់វែងនោះឡើយ ដោយគ្រាន់តែធ្វើការប៉ាន់ស្មានតាមរយៈ Beaufort Scale ដោយពឹងផ្អែកទៅលើចលនារបស់ដើមរុក្ខជាតិ ទង់ជាតិ និងផ្សេងនោះគ្រប់គ្រាន់ហើយ (អានទំព័រទី 6 ឬដើម្បីទទួលយកពត៌បន្ថែម សូមបើលមើលវ៉ិបសាយ www.bom.gov.au/lam/glossary/beaufort.shtml)។

អ្នកក៏ត្រូវធ្វើការកត់ត្រាផងដែរ នូវការប្រែប្រួលសំខាន់ៗអំពីធាតុអាកាសនៅក្នុងពេលប្រើប្រាស់ថ្នាំ។ ឧទាហរណ៍ នៅពេលដែលមានការប្រែប្រួលធាតុអាកាស វាអាចបង្កើនផលប៉ះពាល់ដល់វត្ថុដទៃទៀតដែលអាចកើតមានឡើង ដោយសារការសាយភាយនៃថ្នាំ។

ស្ថានភាពខ្យល់ដែលល្អបំផុតសំរាប់ការប្រើប្រាស់ថ្នាំនោះ គឺនៅពេលដែលខ្យល់បក់ស្រាលៗ ហើយស្មើ ចេញពីតំបន់ដែលងាយនឹងទទួលរងនូវផលប៉ះពាល់។ *Spray Drift Management Principles, Strategies and Supporting Information*[1] មានផ្តល់នូវសេចក្តីណែនាំមួយចំនួន។

ប្រសិនបើថ្នាំដែលអ្នកបានប្រើនោះពុំរសាត់តាមខ្យល់ អ្នកពុំចាំបាច់ធ្វើការកត់ត្រាលំអិតអំពីធាតុអាកាសទេ។ ឧទាហរណ៍ ការត្រាំផ្លែឈើ ឬបន្លែបន្ទាប់ពីការប្រមូលផល ឬការដាក់ពង្រាយនុយបំពុលសត្វចង្រៃ។

## តើខ្ញុំត្រូវធ្វើការកត់ត្រាលំអិតអំពីធាតុអាកាសបន្ថែមពីលើខ្យល់ដែរឬទេ?

សំរាប់ថ្នាំប្រភេទខ្លះ អាជ្ញាធរជាតិទទួលបន្ទុកការចុះបញ្ជី (APVMA) បានដាក់កំណត់នៅលើសញ្ញាសំគាល់ដែលមានបិទភ្ជាប់មកជាមួយផលិតផលឲ្យប្រើប្រាស់ថ្នាំនោះ តែនៅក្នុងស្ថានភាពធាតុអាកាសមួយជាក់លាក់ប៉ុណ្ណោះ។ អ្នកត្រូវធ្វើការកត់ត្រានូវភ្លៀង សីតុណ្ហភាព និង/ឬសំណើម ប្រសិនបើពត៌មានទាំងនេះមានបញ្ជាក់នៅក្នុងសញ្ញាសំគាល់របស់ផលិតផល។ ឧទាហរណ៍ ប្រសិនបើសញ្ញាសំគាល់ដែលមាននៅលើផលិតផលនោះសរសេរថា ʹហាមប្រើប្រាស់ថ្នាំនេះបើដឹងថាភ្លៀងនឹងធ្លាក់ក្នុងកំឡុងពេល៦ម៉ោងបន្ទាប់ពីបានបាញ់ថ្នាំនេះʹ នោះអ្នកក៏គួរតែធ្វើការកត់ត្រាអំពីភ្លៀងដែលរំពឹងទុកនោះផងដែរ។ ស្រដៀងគ្នានេះដែរ ប្រសិនបើសញ្ញាសំគាល់នោះសរសេរថា ʹហាមប្រើប្រាស់នៅពេលសីតុណ្ហភាពកើនលើសពី២៧អង្សាសេ ឬ ʹជៀសវាងប្រើប្រាស់នៅពេលមានសំណើមមានកំរិតទាបជាង៤០ភាគរយʹ នោះអ្នកត្រូវធ្វើការកត់ត្រាពត៌មានអំពីសីតុណ្ហភាព និងសំណើម។

ប្រសិនបើអ្នកតម្រូវឲ្យធ្វើការកត់ត្រាអំពីភ្លៀង សីតុណ្ហភាព ឬសំណើម នោះអ្នកក៏ត្រូវធ្វើការកត់ត្រាផងដែរអំពីការប្រែប្រួលផ្សេងៗ ដែលកើតមានឡើងនៅក្នុងពេលប្រើប្រាស់ថ្នាំ។ ឧទាហរណ៍ ប្រសិនបើធាតុអាកាសមានការប្រែប្រួលនោះ វានាំឲ្យមានការកើនឡើងនូវផលប៉ះពាល់ ដែលកើតមានឡើងដោយសារការសាយភាយនៃថ្នាំ។

---

[1] DPI, 2002, *Spray Drift Management Principles, Strategies and Supporting Information*, NSW Department of Primary Industries, Sydney <www.dpi.nsw.gov.au/aboutus/resources/bookshop/spray-drift-management>.

### តើខ្ញុំអាចធ្វើការកត់ត្រានូវពត៌មានដដែលៗនៅកន្លែងតែមួយបានឬទេ?

បាន។ ពត៌មានខ្លះអាចនៅដដែលៗ នៅពេលប្រើប្រាស់ថ្នាំពីមួយពេល ទៅមួយពេលទៀត។ ដូច្នេះអ្នកអាចកត់ត្រាវាទុកតែមួយកន្លែងសំរាប់ជាពត៌មានយោងនៅរាល់ពេលដែលអ្នកត្រូវកត់ត្រានៅលើកក្រោយ ដោយពុំចាំបាច់ធ្វើការកត់ត្រានូវពត៌មានដដែលនោះឡើងវិញទេ។

ឧទាហរណ៍ អ្នកអាចរក្សាសៀវភៅមួយក្បាលដោយមានកត់ឈ្មោះ និងពត៌មានលំអិតពាក់ព័ន្ធទៅនឹងអ្នកដែលប្រើប្រាស់ថ្នាំនៅលើដីរបស់អ្នក និងបញ្ជីឈ្មោះពេញរបស់ថ្នាំដែលប្រើប្រាស់ជាប្រចាំ ព្រមទាំងគំនូសពង្រាងនៃដីរបស់អ្នក ដោយមានដាក់ឈ្មោះបញ្ជាក់បង្ហាញអំពីកន្លែង ឬផ្នែកណាមួយដែលធ្វើការដាំដុះ។ នៅពេលកត់ត្រា អ្នកគ្រាន់តែយោងទៅឈ្មោះផ្នែកណាមួយនោះ ប្រភេទថ្នាំដែលបានប្រើ និងឈ្មោះអ្នកដែលបានប្រើប្រាស់ថ្នាំ ដោយពុំចាំបាច់សរសេរដដែលៗឡើងវិញទេ។

### តើខ្ញុំត្រូវការពាក្យបំពេញកត់ត្រាពិសេសដែរឬទេ?

អ្នកពុំចាំបាច់មានពាក្យបំពេញកត់ត្រាពិសេសណាមួយសំរាប់កត់ត្រានោះទេ ដោយគ្រាន់តែប្រើទំរង់សមរម្យណាមួយបានហើយ។ អ្នកប្រហែលជាធ្លាប់បានថែរក្សារួចមកហើយនូវឯកសារសំរាប់កម្មវិធីធានាគុណភាព (quality assurance programs) ហើយឯកសារទាំងនោះនឹងមានលក្ខណៈគ្រប់គ្រាន់ ប្រសិនបើវាបញ្ជាក់នូវពត៌មានដែលមានបញ្ជាក់នៅទីនេះ។ ប្រសិនបើកំណត់ត្រារបស់អ្នកពុំមានពត៌មានគ្រប់គ្រាន់ទេ នោះអ្នកត្រូវបន្ថែមនូវពត៌មានដែលខ្វះនោះ។ អ្នកពុំតម្រូវឲ្យរក្សាឯកសារទាំងនោះជាពីរច្បាប់ទេ។

ការបង្កើតរបៀបផ្ទាល់ខ្លួន សំរាប់កត់ត្រាការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ ជារបៀបងាយស្រួលបំផុត។ អាជ្ញាធរការពារបរិស្ថាន (DECCW) បានបង្កើតក្រដាសបំពេញជាគំរូដ៏ងាយស្រួលមួយ (មើលទំព័រទី 7) ដើម្បីជួយសំរួលដល់អ្នកដែលពុំចង់បង្កើតរបៀបកត់ត្រាដោយខ្លួនឯង។ អ្នកអាចប្រើប្រាស់ពាក្យបំពេញនេះជាគំរូ ប្រសិនបើអ្នកចង់។ ឯកសារនោះអ្នកអាចរកបានពីវ៉ិបសាយ DECCW នៅត្រង់ www.environment.nsw.gov.au/pesticides/pestrecords.htm ឬតាមរយៈទូរស័ព្ទ Environment Line លេខ 131 555។

## តើខ្ញុំត្រូវធ្វើកំណត់ត្រានៅពេលណា?

អ្នកត្រូវធ្វើកំណត់ត្រានៅក្នុងកំឡុងពេល២៤ម៉ោង នៃការប្រើប្រាស់ថ្នាំនោះ។

## តើខ្ញុំត្រូវធ្វើកំណត់ត្រាដែរឬទេ បើខ្ញុំគ្រាន់តែប្រើថ្នាំទាំងនោះក្នុងបរិមាណដ៏តិចតួចប៉ុណ្ណោះ?

គ្រប់អាជីវកម្មទាំងអស់ (រួមបញ្ចូលទាំងអ្នកថែរក្សាធ្លាសាធារណៈ ម្ចាស់ហាងផ្សេងៗ) អាជ្ញាធរសាធារណៈ ម្ចាស់ដីជួល អ្នកថែរក្សាបរិស្ថានដែលបានប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ ក្នុងបរិមាណដ៏តិចតួចនៅក្នុងផ្ទះ ហើយការប្រើប្រាស់នោះធ្វើឡើងដោយដៃ ឬឧបករណ៍ដែលប្រើដោយដៃ ពុំតម្រូវឲ្យធ្វើកំណត់ត្រាលើការប្រើប្រាស់ទាំងអស់នោះទេ។

ប្រសិនបើការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃនោះជាផ្នែកមួយនៃអាជីវកម្ម ឬតួនាទីរបស់ខ្លួនដូចដែលបានបញ្ជាក់ខាងលើ អ្នកពុំតម្រូវឲ្យធ្វើកំណត់ត្រាទេ ដូចនៅក្នុងករណីខាងក្រោម**ទាំងនេះ**

- អ្នកប្រើប្រាស់ថ្នាំដែលអាចប្រើបានតែក្នុងផ្ទះ ឬក្នុងសួន **និង**
- អ្នកប្រើប្រាស់ថ្នាំទាំងនោះក្នុងបរិមាណតិចតួច ពោលគឺ:
  - អ្នកប្រើប្រាស់ថ្នាំនៅទីវាលនៅក្នុងបរិមាណមួយតិចជាង ៥លីត្រ/៥គីឡូក្រាមនៃមេថ្នាំ/២០លីត្រ/២០គីឡូក្រាមនៃប្រភេទថ្នាំដែលលាយរួចជាស្រេច ឬ
  - ប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃក្នុងអាគារ ឬផ្ទះដោយមានបរិមាណតិចជាង១លីត្រ/១គីឡូក្រាមនៃមេថ្នាំ/៥លីត្រ/៥គីឡូក្រាមនៃថ្នាំដែលលាយរួចជាស្រេច **ហើយ**
- អ្នកប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃទាំងនោះដោយដៃ ឬប្រើឧបករណ៍ដែលដើរដោយដៃប៉ុណ្ណោះ។

សូមចងចាំថា ទោះបីជាអ្នកស្ថិតនៅក្នុងកាលៈទេសៈដែលអ្នកមិនតម្រូវឲ្យធ្វើកំណត់ត្រាក៏ដោយ ក៏អ្នកត្រូវតែមានការទទួលខុសត្រូវចំពោះការប្រើប្រាស់ដ៏ត្រឹមត្រូវ និងប្រុងប្រយ័ត្នគ្រប់ពេលវេលា។ ប្រសិនបើអ្នកត្រូវបានគេរកឃើញថា ពុំបានប្រើប្រាស់ថ្នាំទាំងនោះត្រឹមត្រូវតាមសេចក្ដីណែនាំទេ អ្នកនឹងត្រូវទទួលនូវការពិន័យសំរាប់ការប្រើប្រាស់ពុំត្រឹមត្រូវនោះ។

## កំណត់ត្រាមួយ សំរាប់ការងារមួយ

ប្រសិនបើអ្នកប្រើប្រាស់ប្រភេទថ្នាំតែមួយទៅលើដីស្រែ ឬចំការដំណាំ ផ្នែកណាមួយនៃចិញ្ចើមថ្នល់ដែលទាំងអស់នេះជាផ្នែកមួយនៃការងារដូចគ្នាសំរាប់ថ្ងៃតែមួយ អ្នកតម្រូវឲ្យធ្វើកំណត់ត្រាតែមួយប៉ុណ្ណោះ ដោយគ្រាន់តែបញ្ជាក់អំពីវាលស្រែ ឬចំការ ដំណាំ ឬផ្នែកណាមួយនៃផ្លូវដែលអ្នកបានប្រើថ្នាំនោះ។

ឧទាហរណ៍ ប្រសិនបើអ្នកបាញ់ប្រភេទថ្នាំលាយតែមួយប្រភេទទៅលើប៉េងប៉ោះ និងត្រសក់ ជាផ្នែកនៃការងារតែមួយ អ្នកអាចធ្វើកំណត់ត្រាតែមួយសំរាប់ការងារនោះ។ អ្នកពុំចាំបាច់ធ្វើការកត់ត្រាពីរផ្សេងពីគ្នាឡើយ។

ចូរចងចាំថា កំណត់ត្រាទាំងនោះដាច់ខាតត្រូវធ្វើឡើងនៅក្នុងអំឡុងពេល២៤ម៉ោងនៃការប្រើប្រាស់ថ្នាំ។ ប្រសិនបើការងាររបស់អ្នកមានរយៈពេលលើសពីមួយថ្ងៃ អ្នកត្រូវធ្វើការកត់ត្រានៅថ្ងៃទីមួយនៃការប្រើប្រាស់ថ្នាំនោះ ហើយបន្ទាប់មកបន្ថែមនូវពត៌មានលំអិតនៃការងារដែលអ្នកបានធ្វើបន្ត។ អ្នកពុំចាំបាច់ធ្វើការកត់ត្រាឡើងវិញសារជាថ្មី ជារៀងរាល់ថ្ងៃទេ។

## *ចុះចំណែកការងារដែលធ្វើឡើងជាក្រុមវិញ?*

នៅពេលដែលក្រុមមនុស្សធ្វើការសំរាប់អាជ្ញាធរសាធារណៈធ្វើការរួមគ្នាជាក្រុម ដូចជាក្រុមអ្នកធ្វើការសាលាក្រុងដើម្បីកំចាត់រុក្ខជាតិចង្រៃ នោះអ្នកគ្រប់គ្រងការងារនៅការដ្ឋានផ្ទាល់ មាននាទីជាអ្នកធ្វើកំណត់ត្រាតែមួយសំរាប់ក្រុមរបស់គេ ដោយរួមបញ្ចូលនូវឈ្មោះសមាជិកទាំងអស់ដែលជាអ្នកប្រើប្រាស់ថ្នាំ។ នេះគឺសំដៅទៅលើការប្រើប្រាស់ឧបករណ៍ប្រើដោយដៃ និងដើរដោយដៃ។ ប្រសិនបើប្រើប្រាស់ឧបករណ៍ ដែល**ពុំប្រើប្រាស់ដោយដៃ** នោះអ្នកប្រើប្រាស់ថ្នាំទាំងអស់ត្រូវធ្វើកំណត់ត្រាដោយផ្ទាល់រៀងៗខ្លួន។

## *តើអ្នកណាជាអ្នកធ្វើកំណត់ត្រា?*

នេះគឺជាការទទួលខុសត្រូវរបស់ជនគ្រប់រូបដែលបានប្រើប្រាស់ថ្នាំ ដើម្បីឲ្យបានប្រាកដថាកំណត់ត្រាអំពីការប្រើប្រាស់ថ្នាំមានភាពត្រឹមត្រូវ។

- ប្រសិនបើអ្នកជាអ្នកប្រើប្រាស់ថ្នាំនោះ នោះខ្លួនអ្នកត្រូវធ្វើកំណត់ត្រាមួយ ឬប្រាកដថាបានធ្វើកំណត់ត្រាមួយដែលមានលក្ខណៈគ្រប់គ្រាន់ត្រឹមត្រូវសំរាប់អ្នក។
- ប្រសិនបើអ្នកជាអ្នកគ្រប់គ្រងការដោយផ្ទាល់នៅលើការដ្ឋានសំរាប់សាលាក្រុងណាមួយ ឬជាភ្នាក់ងាររដ្ឋាភិបាល (ទោះបីអ្នកជាអ្នកធ្វើការដោយស្ម័គ្រចិត្ត ឬជាអ្នកធ្វើការដើម្បីប្រាក់កំរៃក៏ដោយ) ហើយក្រុមរបស់អ្នកបានប្រើប្រាស់ថ្នាំនោះដោយដៃ ឬដោយឧបករណ៍ប្រើដៃប៉ុណ្ណោះ (ដូចជាប្រដាប់ស្ពាយ) ឬបច្ចេកទេសកាត់ និងលាបជាដើម) នោះអ្នកត្រូវតែធ្វើកំណត់ត្រា។
- ប្រសិនបើអ្នកប្រើប្រាស់ឧបករណ៍ដែលដើរដោយថាមពល (ដូចជាម៉ាស៊ីនបាញ់ (boom-sprayer) ប្រដាប់ខ្លងពិនិត្យដី (ground-rig) ជាដើម) ជាផ្នែកមួយនៅក្នុងការរួមរបស់អ្នកនោះ រាល់សមាជិកក្រុមទាំងអស់របស់អ្នកត្រូវធ្វើកំណត់ត្រាផ្ទាល់ខ្លួនម្នាក់មួយសំរាប់ខ្លួនគេ

**ត្រូវធ្វើកំណត់ត្រាជាភាសាអង់គ្លេស។**

## *តើខ្ញុំអាចឲ្យអ្នកផ្សេងទៀតធ្វើកំណត់ត្រាឲ្យខ្ញុំបានឬទេ?*

បាន - អ្នកណាក៏មានសិទ្ធិធ្វើកំណត់ត្រាឲ្យអ្នកបានដែរ ក៏ប៉ុន្តែវាអាស្រ័យទៅលើរូបអ្នក ដែលជាអ្នកប្រើប្រាស់ថ្នាំនោះដោយផ្ទាល់ដើម្បីឲ្យប្រាកដថាកំណត់ត្រានោះធ្វើឡើងដោយត្រឹមត្រូវ។

## *តើអ្នកណាជាអ្នកថែរក្សាកំណត់ត្រា?*

- ប្រសិនបើអ្នកជាម្ចាស់កម្មសិទ្ធ ឬជាអ្នកគ្រប់គ្រង ហើយដែលអ្នក ឬបុគ្គលិករបស់អ្នកជាអ្នកប្រើប្រាស់ថ្នាំទាំងនោះ នោះអ្នកគឺជាអ្នកថែរក្សាកំណត់ត្រាសំរាប់រាល់ការប្រើប្រាស់ថ្នាំទាំងនោះ។
- ប្រសិនបើអ្នកជាអង្គភាពអាជីវកម្ម ហើយបុគ្គលិករបស់អ្នកជាអ្នកប្រើប្រាស់ថ្នាំទាំងនោះ នោះអ្នក (អង្គភាពអាជីវកម្ម) គឺជាអ្នកដែលត្រូវថែរក្សារាល់កំណត់ត្រាដែលបុគ្គលិករបស់អ្នកបានធ្វើ។
- អ្នកតម្រូវឲ្យចម្លងកំណត់ត្រាទាំងអស់ដែលអ្នកបានធ្វើ ទៅឲ្យម្ចាស់ដី ឬអ្នកគ្រប់គ្រងដី ប្រសិនបើអ្នកជាអ្នកម៉ៅការដែលកំពុងធ្វើការឲ្យ:
  - អាជ្ញាធរសាធារណៈ ឬ
  - ធ្វើការនៅវាលលេងហ្គោល ឬ វាលលេងប៊ូល ឬ
  - ធ្វើការនៅក្នុងវិស័យកសិកម្ម ធ្វើស្រែចំការ ឬនៅក្នុងវិស័យរុក្ខាប្រមាញ់
- អាជ្ញាធរសាធារណៈត្រូវធ្វើការថែរក្សាច្បាប់ចម្លងនៃកំណត់ត្រាទាំងអស់ដែលធ្វើឡើងដោយអ្នកម៉ៅការ ឬបុគ្គលិក។

## *តើខ្ញុំត្រូវរក្សាទុកកំណត់ត្រារយៈពេលយូរប៉ុណ្ណា?*

រាល់កំណត់ត្រាទាំងអស់ត្រូវធ្វើការរក្សាទុករយៈពេលបីឆ្នាំ។

## *តើមានរឿងអ្វីកើតឡើងប្រសិនបើខ្ញុំមិនគោរពតាម?*

ស្ថានភាព ឬឧបត្ថិហេតុនីមួយៗត្រូវបានវាយតម្លៃដោយ DECCW តាមមូលដ្ឋានមួយករណីម្តងៗ។ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាអ្នកណាម្នាក់ពុំបានគោរពតាមបទបញ្ញតិនេះ DECCW នឹងពិចារណាមើលថាតើត្រូវធ្វើការព្រមានអ្នកប្រព្រឹត្តខុស ឬពិន័យជាប្រាក់ ឬធ្វើការផ្តន្ទាទោសតាមច្បាប់។ *គោលការណ៍ស្តីពីការផ្តន្ទាទោសរបស់អាជ្ញាធរការពារបរិស្ថាន (EPA Prosecution Guidelines)*បានកំណត់គោលការណ៍ EPA[2] ស្តីអំពីការចេញលិខិតផាកពិន័យ និងនាំខ្លួនអ្នកប្រព្រឹត្តខុសឲ្យតុលាការធ្វើការកាត់ទោស។

ការផាកពិន័យចំពោះការប្រព្រឹត្តផ្ទុយនឹងគោលការណ៍ថែរក្សាកំណត់ត្រា គិតជាប្រាក់ចាប់ពី $150 ដល់ $750 សំរាប់បុគ្គលផ្ទាល់ និង $300 ដល់ $1500 សំរាប់សាជីវកម្ម។ ការផាកពិន័យខ្ពស់បំផុតសំរាប់ការកាត់ទោសគឺ $22,000 សំរាប់បុគ្គលផ្ទាល់ និង $44,000 សំរាប់សាជីវកម្ម។

DECCW ចាត់ចែងកម្មវិធីជម្រះបញ្ជី ដើម្បីត្រួតពិនិត្យការអនុលោមទៅតាមច្បាប់ប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ មានរួមទាំងការថែរក្សាកំណត់ត្រាផងដែរ។ DECCW ក៏ធ្វើការស៊ើបអង្កេតផងដែរអំពីករណីចោទប្រកាន់នៃការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃពុំត្រឹមត្រូវ។ ភ្នាក់ងារ DECCW ដែលមានការអនុញ្ញាតនឹងបង្ហាញជូនអ្នកនូវប័ណ្ណអនុញ្ញាតរបស់គេ ដោយមានរូបថតបញ្ជាក់ផង មុនពេលចាប់ផ្តើមការជម្រះបញ្ជី ឬការស៊ើបអង្កេតណាមួយ។

## *ពត៌មានបន្ថែម*

ពត៌មានបន្ថែម និងជំនួយអាចទទួលយកបានពី Environment Line តាមទូរស័ព្ទលេខ 131 555 (ថ្លៃប្រើប្រាស់ទូរស័ព្ទក្នុងតំបន់ ពីគ្រប់ទីកន្លែងក្នុងរដ្ឋញូវសៅវែល) ឬពីវ៉ិបសាយរបស់ DECCW: www.environment.nsw.gov.au/pesticides/pesticides.htm។

ប្រសិនបើអ្នកចង់អញ្ជើញភ្នាក់ងារ DECCW ឲ្យទៅជួបអ្នក ឬសមាគមរបស់អ្នក សូមទូរស័ព្ទ Environment Line លេខ 131 555។

[2] The Environment Protection Authority (EPA) គឺជាផ្នែកនៃ DECCW.

# មាត្រដ្ឋានបូហ្វ៊ត (Beaufort Scale)

កំណែមាត្រដ្ឋានបូហ្វ៊ត (Beaufort Scale) នេះសំរាប់ជាជំនួយដល់កសិករទាំងអស់ក្នុងការកត់ត្រាល្បឿនខ្យល់ នៅពេលប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ។

| មាត្រដ្ឋានបូហ្វ៊ត ឬលេខតំណាង កម្លាំងខ្យល់ | ល្បឿនខ្យល់ គីឡូម៉ែត្រ / ម៉ោង (គ.ម / ម៉) | បរិយាយ |
|---|---|---|
| 0 | ទាបជាង 1.6 | ស្ងប់ខ្យល់: ផ្សែងហើរត្រង់ឡើងទៅលើ |
| 1 | 1.6 – 4.8 | កង្ហារកំណត់ទិសដៅខ្យល់ (weather vane) ពុំធ្វើចលនា ផ្សែងរសាត់ |
| 2 | 6.4 – 11.3 | ស្លឹកឈើបក់កកិតគ្នាតិចៗ អ្នកដឹងថាមានខ្យល់រសាត់ប៉ះផ្ទៃមុខរបស់អ្នក កង្ហារកំណត់ទិសដៅខ្យល់ (weather vane) ពុំធ្វើចលនា |
| 3 | 12.9 – 19.3 | ស្លឹកឈើ និងមែកតូចៗរញ្ជួយតិចៗ ទង់ជាតិស្រាលល្មមបក់លាតសន្ធឹងតាមខ្យល់ |
| 4 | 20.9 – 29.0 | មែកឈើតូចៗកំរើក ធូលីដី និងក្រដាសប៉ើងដោយសារខ្យល់ |
| 5 | 30.6 – 38.6 | ដើមឈើតូចៗកំរើក ឬ យោលយោកដោយសារខ្យល់ |

***កំណត់សំគាល់:*** តារាងនេះមានដាក់ចុះតែផ្នែកល្បឿនខ្យល់ទាបជាងនៃមាត្រដ្ឋានបូហ្វ៊តប៉ុណ្ណោះ។ មាត្រដ្ឋានបូហ្វ៊តពេញលេញ ក៏មានរួមទាំងលេខតំណាងកម្លាំងខ្យល់ផងដែរ ដែលរៀបរាប់អំពីល្បឿនខ្យល់ដែលខ្លាំងជាង។

ប្រភព: www.bom.gov.au/lam/glossary/beaufort.shtml

# Pesticides: Example record keeping form ថ្នាំសម្លាប់សត្វចង្រៃ៖ តារាងគំរូសំរាប់ធ្វើការកត់ត្រា

**Note:** It is not compulsory to use this format. This example form was developed to assist market gardeners.
If you use a short name for something in filling out this form, you must write the full name somewhere else such as a book or farm diary.

កំណត់ចំណាំ៖ អ្នកពុំតម្រូវដាច់ខាតឲ្យប្រើប្រាស់តារាងគំរូនេះទេ។ តារាងគំរូនេះបង្កើតឡើងដើម្បីជាជំនួយដល់កសិករដែលប្រកបរបរដាំបន្លែ។ ប្រសិនបើអ្នកប្រើឈ្មោះជាអក្សរកាត់សំរាប់ការបំពេញនៅក្នុងតារាងនេះ អ្នកត្រូវកត់ឈ្មោះរបស់វានៅកន្លែងផ្សេងទៀត ដូចជានៅក្នុងសៀវភៅ ឬកំណត់ហេតុកសិដ្ឋានជាដើម។

**Pesticides application record sheet** បញ្ជីកំណត់ត្រាការប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃ

**Record the name, address and contact details of the owner or occupier of the land where the pesticide was applied:**
កត់ត្រាឈ្មោះ អាសយដ្ឋាន និងព័ត៌មានលំអិតរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងដីដែលប្រើប្រាស់ថ្នាំសម្លាប់សត្វចង្រៃនោះ

| Date, start and finish time<br>ថ្ងៃខែឆ្នាំ ពេលចាប់ផ្តើម និងពេលឈប់ | Operator details<br>ព័ត៌មានលំអិតអំពីអ្នកប្រើប្រាស់ | Crop or place where pesticide was applied<br>ឈ្មោះដំណាំ ឬទីកន្លែងដែលប្រើប្រាស់ថ្នាំ | Type of equipment used<br>ប្រភេទឧបករណ៍ដែលប្រើ | Name of pesticide used<br>ឈ្មោះថ្នាំដែលប្រើ | Amount of concentrated product used<br>បរិមាណមេថ្នាំសុទ្ធដែលប្រើ | Total quantity applied<br>បរិមាណសរុបនៃថ្នាំដែលប្រើ | Size of block sprayed<br>ទំហំទីកន្លែងដែលបាញ់ថ្នាំ | Order blocks were treated<br>លំដាប់លំដោយទីកន្លែងដែលប្រើថ្នាំ | Estimated wind speed and direction<br>• ការប៉ាន់ស្មានអំពីល្បឿនខ្យល់ និងទិសដៅខ្យល់ | Other weather details<br>• ព័ត៌មានលំអិតផ្សេងៗអំពីធាតុអាកាស |
|---|---|---|---|---|---|---|---|---|---|---|
|  |  |  |  |  |  |  |  |  | <br> |  |
| | *Name, address and contact details*<br>*ឈ្មោះ អាស័យដ្ឋាន និងលេខទូរស័ព្ទ* | *Also record spraying of fallow land and any pesticides used in and around crops**<br>*កត់ត្រាផងដែរអំពីការបាញ់ថ្នាំទៅលើដីពុំប្រើប្រាស់ ឬថ្នាំសម្លាប់សត្វចង្រៃនៅក្នុង ឬជុំវិញដំណាំ** | | *Record all the pesticides you used.*<br>*កត់ត្រារាល់ប្រភេទថ្នាំដែលប្រើ។* | *If you mixed two pesticides together, you can record both on the same form.*<br>*ប្រសិនបើអ្នកប្រើថ្នាំពីរប្រភេទបញ្ចូលគ្នាអ្នកអាចកត់ត្រាថ្នាំទាំងនោះនៅលើតារាងតែមួយបាន* | *Total amount of water, oil or other things mixed with the concentrated product.*<br>*បរិមាណសរុបនៃទឹក ប្រេង និងវត្ថុផ្សេងទៀតដែលប្រើជាមួយមេថ្នាំ* | *Refer to your farm map***<br>*យោងទៅផែនទីតាំងរបស់កសិដ្ឋាន*** | *Write which block was sprayed first, second, third, etc.*<br>*កត់ត្រាអំពីផ្នែកណាមួយនៃដីដែលបាញ់ថ្នាំមុនគេ បន្ទាប់មកទី២ និងទី៣។ល។* | *If these conditions change significantly during spraying then also record the changes.*<br>*ប្រសិនបើធាតុអាកាសមានការប្រែប្រួលខ្លាំងក្នុងពេលបាញ់ថ្នាំ ត្រូវធ្វើការកត់ត្រាការប្រែប្រួលទាំងនោះផង* | *Only if they are specified on the label or Australian Pesticides and Veterinary Medicines Authority permit.*<br>*ក្នុងករណីដែលបានបញ្ជាក់នៅលើផ្លាក ឬច្បាប់អនុញ្ញាតរបស់អាជ្ញាធរអូស្ត្រាលីទទួលបន្ទុកការចុះបញ្ជីថ្នាំសម្លាប់សត្វចង្រៃ ការព្យាបាលសត្វ និងថ្នាំពេទ្យ* |
| | | | | | | | | | Speed ល្បឿន \| Direction ទិសដៅ | |

* អ្នកពុំតម្រូវដាច់ខាតឲ្យធ្វើការកត់ត្រាអំពីឈ្មោះសត្វចង្រៃ និងប្រភេទជម្ងឺដែលប្រើថ្នាំទាំងនោះទេ ក៏ប៉ុន្តែសំរាប់ការអនុវត្តន៍មួយដ៏ប្រសើរនោះអ្នកគួរតែធ្វើការកត់ត្រាវា។
** អ្នកគួរតែមានផែនទីទីតាំងកសិដ្ឋានរបស់អ្នក ពីព្រោះវាជួយសំរួលអ្នកក្នុងការធ្វើការកត់ត្រានេះ។

**(Records must be in English)**
(ត្រូវធ្វើកំណត់ត្រាជាភាសាអង់គ្លេស)

© Copyright State of NSW and Department of Environment, Climate Change and Water NSW.
អាកាសធាតុ និងទឹក និងរដ្ឋញូវសៅវែលពេញចិត្តនឹងផ្តល់ការអនុញ្ញាតដល់ការបោះពុម្ពផ្សាយនេះដើម្បីឲ្យគេយកទៅផលិតឡើងវិញសំរាប់ការអប់រំ ឬការប្រើប្រាស់មិនមែនសំរាប់គោលបំណងផ្នែកអាជីវកម្មទាំងមូល ឬជាផ្នែក គឺឲ្យតែមិនបានផ្លាស់ប្តូរន័យ ឬប្រភពដើមរបស់វា ហើយមានការទទួលស្គាល់ដល់អ្នកបោះពុម្ពផ្សាយ ហើយនិងអ្នកនិពន្ធ។

បោះពុម្ពដោយៈ
Department of Environment, Climate Change and Water NSW
59 Goulburn Street
PO Box A290
Sydney South 1232
ទូរស័ព្ទ: (02) 9995 5000 (កន្លែងលើកទូរស័ព្ទ)
ទូរស័ព្ទ: 131 555 (ពត៌មានអំពីបរិដ្ឋាន និងការស្នើសុំការបោះពុម្ពផ្សាយ)
ទូរស័ព្ទ: 1300 361 967 (ពត៌មានអំពីសួនឈើក្នុងប្រទេស និងការស្នើសុំការបោះពុម្ពផ្សាយ)
ទូរសារៈ (02) 9995 5999
TTY: (02) 9211 4723
អ៊ីម៉េលៈ info@environment.nsw.gov.au
វ៉ិបសាយៈ www.environment.nsw.gov.au

ISBN 978 1 74232 551 4
DECCW 2010/120
ខែកុម្ភៈ ឆ្នាំ២០១០